# ចំណាប់អារម្មណ៍

## លោកស្រី ធួន សារឹម តំណាងអ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍

## ថ្លែងក្នុងឱកាសប្រារព្ធទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ១ធ្នូ

## ថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៩

## "ទាំងអស់គ្នាចូលរួមជាចរន្តជាតិមួយ ក្នុងការទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍"

- សូមគោរព **ឯកឧត្តមនាយឧត្តមសេនីយ៍ កែ គឹមយ៉ាន ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន** ជាទីគោរពដ៏ខ្ពង់ខ្ពស់
- សូមគោរពគណៈអធិបតី
- សូមគោរពអង្គពិធីទាំងមូល

១) ខ្ញុំឈ្មោះ ធួន សារឹម រស់នៅភូមិទឹកអំបិល ឃុំរវៀង ស្រុកសំរោង ខេត្តតាកែវ។ ខ្ញុំមិនបានដឹងថាមានផ្ទុកមេរោគអេដស៍ទេ នៅពេលដែលខ្ញុំមានទម្ងន់កូនទីប្រាំនៅឆ្នាំ២០០០។ ឆ្នាំ២០០០ ជាឆ្នាំដែលប្ដីខ្ញុំស្លាប់ក្នុងសភាពជំងឺរ៉ាំរ៉ៃ។ ចុងឆ្នាំ២០០១ បងថ្លៃខ្ញុំបានលួងលោមខ្ញុំឱ្យទៅធ្វើតេស្តមេរោគអេដស៍នៅវិជ្ជាស្ថានប៉ាស្ទ័រ ព្រោះគាត់ដឹងថាប្ដីខ្ញុំមានផ្ទុក និងស្លាប់ដោយជំងឺអេដស៍។ បើទោះបីស្ថានភាពផ្ទុកមេរោគអេដស៍របស់ខ្ញុំមិនសូវជាជាក់ច្បាស់នៅឡើយក្ដី ការរើសអើងតាមសហគមន៍នៅក្នុងសម័យកាល២០ឆ្នាំមុននោះមានកម្រិតខ្ពស់ណាស់។ អ្នកជំងឺអេដស៍មួយចំនួនដែលគាត់អង្គុយនៅក្រោមផ្ទះបងប្អូនគាត់ ពេលគាត់ដើរចេញភ្លាមគេសែងគ្រែដែលគាត់អង្គុយយកទៅដុតចោលភ្លាម។ អ្នកជំងឺមួយទៀត ដែលគាត់ផឹកទឹកនឹងកានៅផ្ទះបងប្អូនគាត់ដែរ គាត់ថា ពេលគាត់មកដល់ផ្ទះភ្លាម គេគប់កាទឹកនោះចោលភ្លាម។ គេខ្លាចឆ្លង គេអត់យល់...។ ខ្លួនខ្ញុំផ្ទាល់ ក៏ពិបាករកឆ្មបមកបង្កើតកូនណាស់... អ្នកណាៗក៏គេខ្លាចហើយរើសអើង... ពេលកូនទីប្រាំខ្ញុំកើតចេញមក យូរណាស់ទើបមានយាយឆ្មបបុរាណម្នាក់ហ៊ានមកកាត់សុក។

២) ដោយហេតុថាគ្រួសារខ្ញុំធ្លាក់ខ្លួនក្រខ្លាំង យើងលក់អស់ដីស្រែ គោក្របី និងកេរអាករ ហើយមានកូនច្រើនទៀតនោះ អ្នកជិតខាងខ្លះបានផ្ដល់យោបល់ថាឱ្យយកកូនតូចនេះទៅចោលលើផ្លូវរទេះភ្លើងទៅ។ បើវាមានសំណាងមាននរណាមករើសទាន់ក៏មិនអី គ្មានសំណាងក៏ចប់ត្រឹមនោះលែងមានទុក្ខសោកតទៅទៀត។ ខ្ញុំមិនបានធ្វើតាមគេបង្គាប់ទេ ដោយខ្ញុំនឹកដល់ពាក្យអង្វរ និងបណ្ដាំប្ដីខ្ញុំឱ្យជួយមើលថែកូនផង។ ដូច្នេះ ខ្ញុំក៏នៅតែបន្តជួបការលំបាកជាខ្លាំងនៅក្នុង

ជីវភាពរស់នៅ ព្រោះគ្មានមុខរបរ គ្មានចំណូលចិញ្ចឹមកូនទាំង៥នាក់។ ច្រើនលើកណាស់ដែលខ្ញុំប៉ុនប៉ងលេបថ្នាំសម្លាប់ខ្លួន តែខ្ញុំនៅតែមិនដាច់ចិត្ត ព្រោះបើខ្ញុំស្លាប់ទៅ តើនរណាជួយចិញ្ចឹមកូនទាំង៥នាក់នេះ?

៣) បំណងរបស់គ្រួសារខ្ញុំនៅពេលនោះមានបួន ៖ ១) សុំកុំឱ្យគេរើសអើង ២) សុំឱ្យមានជំនួយស្បៀងអាហារ ៣) សុំឱ្យមានដើមទុនធ្វើមុខរបរចិញ្ចឹមកូន ៤) សុំឱ្យមានសេវាថែទាំសុខភាពដោយមិនយកប្រាក់។ បំណងរបស់គ្រួសារខ្ញុំទាំងនេះគឺមិនខុសពីគ្រួសារដែលរងផលប៉ះពាល់ដោយសារជំងឺអេដស៍ទាំងឡាយដែលចង់បន្តរស់នៅដោយថ្លៃថ្នូរ និងស្មើមុខនឹងគេឯង ទោះមានឬគ្មានមេរោគអេដស៍នោះឡើយ។

៤) ជាបន្ត ខ្ញុំសូមបង្ហាញជូនថា តើបំណងរបស់គ្រួសារខ្ញុំត្រូវបានសម្រេចដូចម្ដេចខ្លះ?
   ១) នៅឆ្នាំ២០០១ ខ្ញុំបានទាក់ទងជាមួយបុគ្គលិកអង្គការដៃគូផ្ដល់មេត្តា (Partner of Compassion, PC) ដែលដឹកនាំដោយលោកគ្រូ **សាន វណ្ណីន**។ ប៉ុន្តែ ពេលនោះនៅមិនទាន់បានទទួលថ្នាំប្រឆាំងមេរោគអេដស៍នៅឡើយទេ ដោយត្រូវរង់ចាំលទ្ធផលចំនួន CD4 តាមនិយាមថែទាំព្យាបាលនៅជំនាន់នោះ។ រហូតដល់ឆ្នាំ២០០៦ ទើបខ្ញុំបានចាប់ផ្ដើមប្រើឱសថប្រឆាំងមេរោគអេដស៍ពីមន្ទីរពេទ្យបង្អែកខេត្តតាកែវ។
   ២) ឥរិយាបថមិនរើសអើងនៃបុគ្គលិកសុខាភិបាល និងអង្គការដៃគូផ្ដល់មេត្តា ក្រុមគ្រូពេទ្យ និងជាពិសេស ក្រុមថែទាំជំងឺអេដស៍តាមផ្ទះបានធ្វើឱ្យអ្នកជិតខាងដែលរើសអើងគ្រួសារខ្ញុំមានការចម្លែកចិត្ត ហើយចាប់ផ្ដើមកែប្រែការប្រព្រឹត្ត ធ្វើឱ្យគ្រួសារខ្ញុំកាន់តែមានលទ្ធភាពបន្តជីវភាពរស់នៅកាន់តែប្រសើរម្ដងបន្តិចៗ។ ខ្ញុំបានប្រែពីចិញ្ចឹមមាន់ ទៅជាទិញមាន់យកមកលក់វិញ។ មុខរបរនេះធ្វើឱ្យខ្ញុំអាចរកចំណូលបាន១០ដុល្លារក្នុងមួយថ្ងៃៗ។
   ៣) ពីឆ្នាំ២០០១ ដល់ឆ្នាំ២០១២ គ្រួសារខ្ញុំបានទទួលជំនួយស្បៀងអាហារពីប្រភពនានា ដោយមានការជ្រោមជ្រែង និងឧបត្ថម្ភពី កាកបាទក្រហមកម្ពុជា និងអង្គការស្បៀងអាហារពិភពលោក។
   ៤) ដោយមានការលើកទឹកចិត្តពីក្រុមគ្រូពេទ្យ និងជាពិសេសក្រុមថែទាំជំងឺអេដស៍តាមផ្ទះ និង ការផ្សព្វផ្សាយទូទៅតាមវិទ្យុ ទូរទស្សន៍ និងតាមសហគមន៍ ការរើសអើងបានថយចុះយ៉ាងខ្លាំង។ ចេញពីប្រាក់ចំណូលដែលបានពីលក់មាន់ ខ្ញុំបានបញ្ជូនកូនៗទាំង៥នាក់ឱ្យទៅរៀនទាំងអស់គ្នា ទោះបីជាមានការលំបាកផ្នែកជីវភាពយ៉ាងណាក្តី។

៥) មកដល់ឆ្នាំ២០១៩ស្ថានភាពគ្រួសារខ្ញុំ ៖
   ១) ខ្ញុំបានទិញដីស្រែគោក្របីទ្រព្យសម្បត្តិដែលបាត់បង់ពី២០ឆ្នាំមុនត្រឡប់មកវិញទាំងអស់
   ២) អ្នកជិតខាងដែលធ្លាប់រើសអើងគ្រួសារខ្ញុំ ឥឡូវបែរជាមករាប់អានគ្រួសារខ្ញុំវិញដោយសារកូនៗខ្ញុំបានរៀនសូត្រខ្ពស់គួរសម និងធ្វើការទាំងអស់គ្នា ៖

- កូនប្រុសទី១ អាយុ៣០ឆ្នាំ ពីមុនជាបុគ្គលិកស្ថានទូតកូរ៉េ និងបច្ចុប្បន្នជាបុគ្គលិកក្រុមហ៊ុនជីបម៉ុង (ជំនាញភាសាកូរ៉េ)។
- កូនស្រីទី២ អាយុ២៨ឆ្នាំ ជាបុគ្គលិក Graphic Design ក្រុមហ៊ុនកាត់ដេរទំនើបបារាំង Colorblind។
- កូនស្រីទី៣ អាយុ២៦ឆ្នាំ ជានិស្សិតអនុបណ្ឌិតផ្នែកសុខមាលភាពសង្គមនៅប្រទេសជប៉ុន។
- កូនប្រុសទី៤ អាយុ២៣ឆ្នាំ ជានិស្សិតឆ្នាំទី៣ ខាងសំណង់ស៊ីវិល នៃសាកល វិទ្យាល័យន័រតុន។
- កូនប្រុសទី៥ អាយុ២០ឆ្នាំ ជានិស្សិតឆ្នាំទី១ ស្ថាបត្យកម្មនៃសាកលវិទ្យាល័យន័រតុន។

៣) ឥឡូវគ្រួសារខ្ញុំមានគេរាប់អានច្រើនគេហៅទៅបុណ្យ និងចូលរួមពិធីរៀបការមិនរំលងទេ។

៦) ជាទីបញ្ចប់ ខ្ញុំសូមបញ្ជាក់ថា ភាពជោគជ័យរបស់គ្រួសារខ្ញុំមិនមែនជាសំណាងដោយឡែករបស់គ្រួសារខ្ញុំនោះទេ។ ខ្លួនខ្ញុំផ្ទាល់នេះជាមនុស្សម្នាក់ក្នុងចំណោមអ្នកផ្ទុកមេរោគអេដស៍ជាង ៦សែននាក់នៅក្នុងប្រទេស ដែលត្រូវបានបញ្ចៀសពីការស្លាប់ដោយជំងឺអេដស៍ ដោយយើងបានទទួលសេវាថែទាំសុខភាព ដោយមិនយកប្រាក់ក្នុងរយៈពេលជាងពីរទសវត្សរ៍កន្លងមក។ គ្រួសារខ្ញុំជាគ្រួសារមួយនៃ ជាង២ម៉ឺនគ្រួសារទទួលរងផលប៉ះពាល់ជំងឺអេដស៍ដែលបានទទួលជំនួយស្បៀងអាហារ រយៈកាលជាង១០ឆ្នាំ គឺពីឆ្នាំ២០០១ ដល់២០១២។

៧) តាងនាមអ្នកផ្ទុកមេរោគអេដស៍ ជាង៧ម៉ឺននាក់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា ឥស្សរជនឆ្នើមថ្នាក់ជាតិនៃវេទិកាភាពជាអ្នកដឹកនាំប្រចាំតំបន់អាស៊ី-ប៉ាស៊ីហ្វិក ឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ ដែលលោកទាំងពីរ បានជួយខ្នះខ្នែងរៀបចំជា គោលនយោបាយ យុទ្ធសាស្ត្រ កសាងធនធានមនុស្ស និងចលនាធនធានប្រយុទ្ធប្រឆាំងមេរោគអេដស៍ប្រកបដោយជោគជ័យនៅប្រទេសកម្ពុជា និងជាពិសេសជួយឱ្យអ្នកជំងឺអេដស៍ទាំងឡាយបន្តរស់នៅក្នុងភាពថ្លៃថ្នូរ និងសុខដុមរមនា ដូចគ្រួសារនានាផងដែរ។

**សូមអរគុណ!**